**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងអប់រំ យុវជន និង កីឡា

លេខ ១១០០ អយក.ប្រក

# ប្រកាស

ស្តីពីការពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ តំបែរ ទៅជាវិទ្យាល័យ ហ៊ុន សែន ចារថ្មី

ស្ថិតនៅក្នុងឃុំចុងជាច ស្រុកតំបែរ ខេត្តកំពង់ចាម

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និង កីឡា

- បានឃើញព្រះរាជក្រឹត្យលេខ នស.រកត ១១៩៨-៧២ ចុះថ្ងៃទី ៣០ ខែ វិច្ឆិកា ឆ្នាំ ១៩៩៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាល នៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រម លេខ ០២ នស-៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ១៩៩៤ ស្តីពីការរៀបចំនិងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រម នស-រកម ០១៩៦-០១ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ស្តីពីការបង្កើតក្រសួងអប់រំយុវជន និងកីឡា
- បានឃើញព្រះរាជក្រឹត្យ លេខ នស-រកត ០៧៩៦-៥២ ចុះថ្ងៃទី ២៦ ខែ កក្កដា ឆ្នាំ ១៩៩៦ ស្តីពីប្រព័ន្ធអប់រំចំនេះទូទៅ ១២ឆ្នាំ
- បានឃើញអនុក្រឹត្យលេខ ២១ អនក្រ-បក ចុះថ្ងៃទី ២៣ ខែ មីនា ឆ្នាំ ១៩៩៨ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញសារាចរណែនាំលេខ ៦៦ អរ-ចទម ចុះថ្ងៃទី ០២ ខែមេសា ១៩៨៣ ស្តីពីការបើកសាលារៀនមធ្យមសិក្សាកំរិត១-កំរិត២
- យោងលិខិតស្នើសុំរបស់អនុវិទ្យាល័យ តំបែរ ឃុំចុងជាច ស្រុកតំបែរ លេខ ៩៧៩ អយក.កច.មស ចុះថ្ងៃទី ០២ ខែ កញ្ញា ឆ្នាំ ២០០៣ ដោយមានយោបល់ឯកភាពពីមន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ចាម
- តាមយោបល់ឯកភាពរបស់នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ

## សំរេច

ប្រការ ១: អនុញ្ញាតអោយពង្រីក និងប្តូរឈ្មោះអនុវិទ្យាល័យ « តំបែរ » បច្ចុប្បន្នទៅជាវិទ្យាល័យ « ហ៊ុន សែន ចារថ្មី » ស្ថិតនៅក្នុងឃុំចុងជាច ស្រុកតំបែរ ខេត្តកំពង់ចាម ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ ។

ប្រការ ២: វិទ្យាល័យនេះត្រូវដឹកនាំដោយនាយកមួយរូប និង នាយករងតាមការចាំបាច់ ព្រមទាំងបុគ្គលិកផ្សេងៗ មួយចំនួនទៀតតាមអង្គការលេខ នៃវិទ្យាល័យ ។

ប្រការ ៣: នាយក-នាយករងនៃវិទ្យាល័យមានសិទ្ធិទទួលប្រាក់បំណាច់ភារកិច្ចតាមគោលការណ៍របស់រដ្ឋ ។

ប្រការ ៤: បទបញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីប្រកាសនេះត្រូវទុកជានិរាករណ៍ ។

ប្រការ ៥: អគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកដ្ឋានអប់រំ នាយកដ្ឋានមធ្យមសិក្សាចំនេះទូទៅ នាយកដ្ឋានបុគ្គលិក នាយកដ្ឋានផែនការ នាយកដ្ឋានហិរញ្ញវត្ថុ ក្រសួងអប់រំ យុវជន និងកីឡា មន្ទីរអប់រំ យុវជន និងកីឡា ខេត្តកំពង់ចាម និងនាយកអនុវិទ្យាល័យសាមី មានភារកិច្ចរៀងៗខ្លួនអនុវត្ត ប្រកាសនេះ ។

ភ្នំពេញ, ថ្ងៃទី ១៤ ខែ តុលា ឆ្នាំ ២០០៣

ជ. រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

រដ្ឋលេខាធិការ

**អ៊ឹម សិទ្ធី**

<u>កន្លែងទទួល:</u>

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចនាយករដ្ឋមន្ត្រី
- រដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
  " ដើម្បីជ្រាបជាពត៌មាន "
- សាលាខេត្តកំពង់ចាម " ដើម្បីជាពត៌មាន "
- ដូចប្រការ ៥
- កាលប្បវត្តិ-ឯកសារ នា.មចទ